# របាយការណ៍សង្ខេបស្ដីពីការវាយតម្លៃបឋម

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ

ក្រសួង: អប់រំ យុវជន និងកីឡា

លេខយោង: ០០០០០

កាលបរិច្ឆេទចាប់ផ្ដើម : ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

អនុក្រឹត្យនេះមានគោលបំណងផ្ដល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រដែលជួបការលំបាកដើម្បីទទួលបានសេវាអប់រំប្រកបដោយសមធម៌នៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ។ ដើម្បីសម្រេចបានគោលបំណងនេះ បញ្ញត្តិកម្មនេះត្រូវបានតាក់តែងឡើងដើម្បីបង្កើនប្រាក់ឧបត្ថម្ភប្រចាំឆ្នាំដល់សិស្សចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ដែលសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈនានា ឱ្យស្របតាមការវិវត្តនៃសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន។ កន្លងមក ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រសម្រាប់ការចូលរៀនដោយសមធម៌នៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅប្រចាំឆ្នាំ ត្រូវបានអនុវត្តតាមអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ដែលមានកម្រិតទាបពេក អាចផ្គត់ផ្គង់សម្ភារសិក្សាជាមូលដ្ឋាន ឯកសណ្ឋានសិស្ស និងមធ្យោបាយធ្វើដំណើរបានតិចតួចនាពេលបច្ចុប្បន្ន។ ថវិកាដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តអនុក្រឹត្យនេះជាបន្ទុកថវិការបស់រដ្ឋ។

ការសិក្សាវាយតម្លៃលើផលប៉ះពាល់នៃគម្រោងដំឡើងប្រាក់អាហារូបករណ៍ដល់សិស្សក្រីក្រសម្រាប់ការចូលរៀនដោយសមធម៌នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅត្រូវបានធ្វើឡើង ដោយផ្ដោតសំខាន់លើជម្រើស៣ មានដូចខាងក្រោម៖

១-ជម្រើសទី១ : អនុវត្តអនុក្រឹត្យថ្មីនេះ ដោយកំណត់វិសាលភាពពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។

២-ជម្រើសទី២ : អនុវត្តអនុក្រឹត្យថ្មីនេះ ដោយកំណត់វិសាលភាពពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២។

៣-ជម្រើសទី៣ : បន្តអនុវត្តអនុក្រឹត្យលេខ៦៦ ដដែល។

ផ្អែកតាមការវិភាគលើបន្ទុកចំណាយថវិការដ្ឋនៃជម្រើសទាំង៣ ខាងលើនេះ បង្ហាញថាជម្រើសទី១ មានបន្ទុកចំណាយថវិការដ្ឋចំនួន ៩០.១៥៥.២៨០.០០០ រៀល (ត្រូវជា២២.៥៣៨.៨២០ ដុល្លារ) ច្រើនជាងជម្រើសទី២ ដែលមានបន្ទុកចំណាយថវិការដ្ឋចំនួន ៣៦.៦៨៤.២៤០.០០០រៀល (ត្រូវជា ៩.១៧១.០៦០ដុល្លារ) និងច្រើនជាងជម្រើសទី៣ ដែលមានបន្ទុកចំណាយថវិការដ្ឋចំនួន ១១.៧៣២.៤០០.០០០រៀល(ត្រូវជា ២.៩៣៣.១០០ដុល្លារ) ប៉ុន្តែរដ្ឋមានលទ្ធភាពក្នុងការចំណាយ។ ទោះជាជម្រើសទី១ មានបន្ទុកចំណាយខ្ពស់ជាងជម្រើស២ និងទី៣ ក៏ដោយ ក៏ការវិភាគលើផលចំណេញនៃជម្រើសទាំង៣នេះ បានបង្ហាញថា ជម្រើសទី១ ផ្ដល់ផលចំណេញផ្នែកសេដ្ឋកិច្ច សង្គមច្រើនជាង ក្នុងចំណោមជម្រើសទាំង៣នេះ ដោយមានសិស្សចំនួន ៣៧៣ ៨៤០នាក់ នឹងត្រូវទទួលបានប្រាក់អាហារូបករណ៍តាមរបបថ្មីនេះ ច្រើនជាងជម្រើសទី២ ដែលមានចំនួន ១៥០ ៦៨៤នាក់ និងច្រើនជាងជម្រើសទី៣ ដែលមានចំនួន ៦៥ ១៨០នាក់។

ដោយឈរលើមូលដ្ឋាននៃផលចំណេញជាចម្បង ជម្រើសទី១ គួរត្រូវបានជ្រើសរើសក្នុងការដោះស្រាយបញ្ហាដូចបានលើកឡើងខាងលើ។

# ការវាយតម្លៃផលប៉ះពាល់បឋម

សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា
និងមធ្យមសិក្សាចំណេះទូទៅ

| | |
|---|---|
| ក្រសួង: | អប់រំ យុវជន និងកីឡា |
| លេខយោង: | ០០០០០ |
| កាលបរិច្ឆេទចាប់ផ្ដើម : | ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ |
| កាលបរិច្ឆេទបញ្ចប់ : | ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ |

**អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម**

(រៀបរាប់ពីចំណុចសំខាន់ៗ ដូចជាកាតព្វកិច្ច វិសាលភាព និងគោលបំណង)

អនុក្រឹត្យនេះ មានគោលបំណងផ្ដល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រដែលជួបការលំបាកដើម្បីទទួលបានសេវាអប់រំប្រកបដោយសមធម៌នៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ។ ដើម្បីសម្រេចបានគោលបំណងនេះ បញ្ញត្តិកម្មនេះត្រូវបានតាក់តែងឡើងដើម្បីបង្កើនប្រាក់ឧបត្ថម្ភប្រចាំឆ្នាំដល់សិស្សចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ដែលសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈនានា ឱ្យស្របតាមការវិវត្តនៃសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន។ កន្លងមក ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាកសម្រាប់ការចូលរៀនដោយសមធម៌នៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅប្រចាំឆ្នាំត្រូវបានអនុវត្តតាមអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ដែលមានកម្រិតទាបពេក អាចផ្គត់ផ្គង់សម្ភារសិក្សាជាមូលដ្ឋាន ឯកសណ្ឋានសិស្ស និងមធ្យោបាយធ្វើដំណើរបានតិចតួចនាពេលបច្ចុប្បន្ន។ ថវិកាដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តអនុក្រឹត្យនេះជាបន្ទុកថវិការបស់រដ្ឋ។ ប្រាក់អាហារូបករណ៍ប្រចាំឆ្នាំនិងចំនួនសិស្សដែលត្រូវទទួលបាន មានដូចខាងក្រោម ៖

- បឋមសិក្សា : ២៤០ ០០០រៀល (ពីមុនគ្មាន)
- មធ្យមសិក្សាបឋមភូមិ : ២៤០ ០០០រៀល (ពីមុន១៨០.០០០រៀល)
- មធ្យមសិក្សាទុតិយភូមិ : ៣៦០ ០០០រៀល (ពីមុនគ្មាន)

ប្រភេទបញ្ញត្តិកម្ម

*សូមគូសសញ្ញាក្នុងប្រអប់ឲ្យត្រូវនឹងប្រភេទបញ្ញត្តិកម្មណាមួយ ហើយសូមអធិប្បាយប្រសិនបើសំណើនោះជាប្រភេទផ្សេងទៀត។*

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្ដីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ ៖

☑ សេដ្ឋកិច្ច ☑ សង្គមកិច្ច □ បរិស្ថាន □ ...ផ្សេងៗ

## ១. ការកំណត់បញ្ហា

*បញ្ហាមានដូចជា សុខភាពនិងសុវត្ថិភាពសាធារណៈ ការការពារ និងអភិរក្សបរិស្ថាន សមធម៌យេនឌ័រ និងសង្គម និងការអភិរក្សវប្បធម៌ ការប្រកួតប្រជែង ការប្រមូលព័ត៌មាន អនុលោមតាម កិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗល។*

**១.ក. បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្ដល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្ដែង ប្រសិនបើចាំបាច់)**

អាហារូបករណ៍សម្រាប់សិស្សក្រីក្រដែលបានផ្ដល់កន្លងមកនៅមានកម្រិតទាបពេក បើធៀបនឹងការវិវត្តនៃសេដ្ឋកិច្ចបច្ចុប្បន្ន។ នៅក្នុងអនុក្រឹត្យលេខ៦៦ ដែលចេញកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ បានផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រក្នុង១ឆ្នាំ ១៨០ ០០០រៀល សម្រាប់សិស្សម្នាក់។ ក្នុងឆ្នាំ២០០៣ ប្រាក់អាហារូបករណ៍នេះ អាចជួយរួមចំណែកលើកទឹកចិត្តខ្លះៗដល់សិស្សនិងអាចប្រើប្រាស់សម្រាប់ការទិញសម្ភារ ឯកសណ្ឋានសិស្ស និងមធ្យោបាយធ្វើដំណើរបាន ក៏ប៉ុន្តែពេលបច្ចុប្បន្ននេះ ចំនួនទឹកប្រាក់នេះមានកម្រិតទាបពេកមិនអាចឆ្លើយតបទៅនឹងតម្រូវការ និងតម្លៃទំនិញនៅលើទីផ្សារ។ ម្យ៉ាងទៀត អនុក្រឹត្យលេខ៦៦នេះ មានអាយុកាល១១ឆ្នាំហើយ។

**១.ខ. បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្ដល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្ដែង ប្រសិនបើចាំបាច់)**

បញ្ញត្តិកម្មនេះនឹងជួយជំរុញឱ្យសម្រេចបាននូវគោលដៅទី២នៃគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដែលបានកំណត់អំពីសកលកម្មអប់រំបឋមសិក្សា ជួយកាត់បន្ថយអត្រាបោះបង់ការសិក្សា ពង្រឹងការរៀនសូត្របានជាប់លាប់របស់សិស្ស ទប់ស្កាត់ការដកហូតកុមារយកទៅធ្វើពលកម្ម បង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងជួយឱ្យសម្រេចបាននូវគោលនយោបាយទី១របស់ក្រសួងអប់រំ យុវជន និងកីឡាដែលធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌។

**១.គ. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។ ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?**

១. អនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ
២. ច្បាប់ស្ដីពីការអប់រំ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
៣. អនុក្រឹត្យលេខ ៦៦ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៣ ស្ដីពីការកំណត់ចំណាយដោយឡែកសម្រាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាកសម្រាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ

*(ពន្យល់ថាតើហេតុអ្វីបានជាបញ្ញត្តិកម្មទាំងនេះមិនដំណើរការ? តើលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនអាចអនុវត្តបានពេញលេញឬ? តើយើងអាចកែលម្អលិខិតបទដ្ឋានគតិយុត្តណាមួយដើម្បីសម្រេចបាននូវគោលបំណងដែលបានកំណត់ដែរឬទេ? តើយើងអាចពង្រឹងការអនុវត្តច្បាប់ដើម្បីដោះស្រាយបញ្ហាបានដែរឬទេ?)*

ច្បាប់និងអនុក្រឹត្យខាងលើមិនបានចែងច្បាស់ស្ដីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាកដើម្បីធានាការចូលរៀនដោយសមធម៌ឡើយ។ ដោយឡែកអនុក្រឹត្យលេខ៦៦ បានចែងច្បាស់អំពីការផ្តល់អាហារូបករណ៍នេះដែរ តែប្រាក់អាហារូបករណ៍នៅមានកម្រិតទាបពេក បើធៀបនឹងការវិវត្តនៃសេដ្ឋកិច្ចជាតិនិងតម្លៃទំនិញនៅលើទីផ្សារនាពេលបច្ចុប្បន្ន។

១.ឃ. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?
(ប្រសិនបើមាន សូមពន្យល់)

បញ្ញត្តិកម្មនេះនឹងមិនមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងឡើយ ដោយហេតុថា បញ្ញត្តិកម្មនេះមិនមានពាក់ព័ន្ធដល់ធុរកិច្ចទេ បញ្ញត្តិកម្មនេះពាក់ព័ន្ធតែជាមួយរាជរដ្ឋាភិបាលតែប៉ុណ្ណោះ។

## ២. គោលបំណង - តើយើងចង់សម្រេចបានអ្វី?

*ចូរបញ្ជាក់អំពីគោលបំណង (លទ្ធផល) ចុងក្រោយ មិនមែនគ្រាន់តែជាលទ្ធផលភ្លាមៗ ឬជាមធ្យោបាយនោះទេ។ (សូមជៀសវាងការលើកឡើងអំពីមធ្យោបាយដើម្បីសម្រេចគោលបំណងនៅចំណុចនេះ)។*

*មិនត្រូវកំណត់គោលបំណងឲ្យចង្អៀតពេកទេដែលរឹតត្បិតជម្រើស តែក៏មិនត្រូវឲ្យទូលំទូលាយពេកឬមិនច្បាស់លាស់ដែលនឹងធ្វើឲ្យការវិភាគមានការលំបាក។ សូមផ្សារភ្ជាប់ទៅនឹងគោលបំណងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រសិនបើពាក់ព័ន្ធ។ ការកៀរគរចំណូលឬបង្កើតឥទ្ធិពលសម្រាប់ស្ថាប័នមិនមែនជាគោលបំណងសមស្របរបស់បញ្ញត្តិកម្មទេ។*

លើកកម្ពស់ការចូលរៀនដោយសមធម៌នៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ដើម្បីឈានទៅសម្រេចគោលនយោបាយទី១របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានកំណត់ថាធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងឈានទៅសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា។

## ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

*(ពិចារណាលើជម្រើសផ្សេងទៀតជាការសំខាន់ ហើយសូមកត់សម្គាល់ថាបញ្ញត្តិកម្មមិនមែនជាជម្រើសដំបូងបង្អស់នោះទេ)*

| |
|---|
| ១. សំណើអនុក្រឹត្យថ្មី ដែលមានវិសាលភាពអនុវត្តចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។<br>២. សំណើអនុក្រឹត្យថ្មី ដែលមានវិសាលភាពអនុវត្តចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២។<br>៣. បន្តអនុវត្តអនុក្រឹត្យលេខ ៦៦ ឆ្នាំ២០០៣។ |

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាក់ព័ន្ធ និងផលចំណេញ

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ (tasks and cost-categories)

*តារាងខាងក្រោមនេះគ្រាន់តែរំលេចពីប្រភេទបន្ទុកចំណាយតែប៉ុណ្ណោះ ពុំចាំបាច់ការគណនាលម្អិតទេ។*

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| សំណើបញ្ញត្តិកម្ម: ……… | | |
| ជម្រើសទី១: អនុវត្តសំណើអនុក្រឹត្យថ្មី ដែលមានវិសាលភាពអនុវត្តពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។ | បន្ទុកចំណាយលើអាហារូបករណ៍ប្រចាំឆ្នាំ | គ្មាន |
| ជម្រើសទី២: អនុវត្តសំណើអនុក្រឹត្យថ្មី ដែលមានវិសាលភាពអនុវត្តពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២។ | បន្ទុកចំណាយលើអាហារូបករណ៍ប្រចាំឆ្នាំ | គ្មាន |
| ជម្រើសទី៣: បន្តអនុវត្តអនុក្រឹត្យលេខ៦៦ ឆ្នាំ២០០៣។ | បន្ទុកចំណាយលើអាហារូបករណ៍ប្រចាំឆ្នាំ | គ្មាន |

### ៤.២. ការកំណត់ប្រភេទនៃផលចំណេញ (benefit-categories)

*តារាងខាងក្រោមនេះរំលេចពីប្រភេទផលចំណេញ។*

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| សំណើបញ្ញត្តិកម្ម: ……… | |
| ជម្រើសទី១: អនុវត្តសំណើអនុក្រឹត្យថ្មីដែលមានវិសាលភាពអនុវត្តចាប់ពី | - សិស្សនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅដែលមានជីវភាពក្រីក្រចំនួន ៣៧៣ ៤៤០នាក់ |

| | |
|---|---|
| ថ្នាក់ទី១ ដល់ថ្នាក់ទី១២។ | (ច្រើនជាងជម្រើសទីពីរ ២១២ ៧៩៦នាក់)នឹងទទួលបានអាហារូបករណ៍តាមរបបថ្មីដែលមានកម្រិតខ្ពស់ជាងជម្រើសទី២។<br>- សមធម៌ក្នុងការទទួលបានសេវាអប់រំស្របតាមគោលនយោបាយទី១របស់ក្រសួង(ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌) មានកម្រិតខ្ពស់ជាងជម្រើសទី២។<br>- ថវិកាបន្ថែមនឹងចរាចរនៅលើទីផ្សារ បង្កើនការទិញ បង្កើនផលិតកម្ម បង្កើនការងារ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ជាងជម្រើសទី២។ |
| ជម្រើសទី២: អនុវត្តសំណើអនុក្រឹត្យថ្មីដែលមានវិសាលភាពអនុវត្តចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២។ | - សិស្សនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅដែលមានជីវភាពក្រីក្រចំនួន ១៥០ ៦៤៨នាក់ (តិចជាងជម្រើសទីមួយ ២១២ ៧៩៦នាក់ តែច្រើនជាងជម្រើសទីបី ៨៥ ៤៦៨នាក់)នឹងទទួលបានអាហារូបករណ៍តាមរបបថ្មីដែលមានកម្រិតទាបជាងជម្រើសទី១ តែខ្ពស់ជាងជម្រើសទី៣ ទាំងតម្លៃអាហារូបករណ៍ ទាំងចំនួនសិស្សទទួលបានអាហារូបករណ៍។<br>- សមធម៌ក្នុងការទទួលបានសេវាអប់រំស្របតាមគោលនយោបាយទី១របស់ក្រសួង(ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌) មានកម្រិតខ្ពស់ជាងជម្រើសទី២។<br>- ថវិកាបន្ថែមនឹងចរាចរនៅលើទីផ្សារ បង្កើនការទិញ បង្កើនផលិតកម្ម បង្កើនការងារ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ជាងជម្រើសទី២។ |
| ជម្រើសទី៣: បន្តអនុវត្តអនុក្រឹត្យលេខ ៦៦ ឆ្នាំ២០០៣។ | - សិស្សអនុវិទ្យាល័យដែលមានជីវភាពក្រីក្រចំនួន ៦៥ ១៨០នាក់ នឹងបានទទួលអាហារូបករណ៍។<br>- សមធម៌ក្នុងការទទួលបានសេវាអប់រំស្របតាមគោលនយោបាយទី១របស់ក្រសួង(ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌) នៅមានកម្រិតទាប។<br>- ថវិកាទទួលបានពីអាហារូបករណ៍នឹងចរាចរនៅលើទីផ្សារ ជំរុញឱ្យមានការទិញ ផលិតកម្ម ហើយរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចក្នុងកម្រិតទាប។ |

៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

*ចូររៀបរាប់អំពីវិស័យ ឬប្រភេទធុរកិច្ចដែលរងឥទ្ធិពល ព្រមទាំងធ្វើការព្យាករផលប៉ះពាល់ពីការអនុវត្តតាមជម្រើសដែលបានស្នើឡើង (សូមផ្តល់ភស្តុតាងដើម្បីគាំទ្រការប៉ាន់ស្មាននេះ)។*

| ជម្រើស | វិស័យ ឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| សំណើបញ្ញត្តិកម្ម: សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ | អប់រំ | | |
| ជម្រើសទី១: អនុវត្តសំណើអនុក្រឹត្យថ្មី ដែលមានវិសាលភាពអនុវត្តពីថ្នាក់ទី១ ដល់ទី១២ | | សិស្សចំនួន ៣៧៣ ៤៨០ នាក់ ទទួលបានអាហារូបករណ៍ | សំណើរបស់នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សា |
| ជម្រើសទី២: អនុវត្តសំណើអនុក្រឹត្យថ្មី ដែលមានវិសាលភាពអនុវត្តពីថ្នាក់ទី៤ ដល់ទី១២ | | សិស្សចំនួន ១៥០ ៦៨៤ នាក់ ទទួលបានអាហារូបករណ៍ | សំណើរបស់នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សា |
| ជម្រើសទី៣: បន្តអនុវត្តអនុក្រឹត្យលេខ៦៦ | | សិស្សចំនួន ៦៥ ១៨០នាក់ ទទួលបានអាហារូបករណ៍ | សំណើរបស់នាយកដ្ឋានមធ្យមសិក្សា |

## ៥. **កិច្ចពិគ្រោះយោបល់បឋម**( ជាមួយអ្នកពាក់ព័ន្ធ )

កិច្ចពិគ្រោះយោបល់នេះមានគោលបំណងធ្វើឲ្យចំណុចខាងលើកាន់តែប្រសើរឡើង។ កិច្ចពិគ្រោះយោបល់ជាមួយសំណាក(Sample)នៃអ្នកពាក់ព័ន្ធ។ សូមធ្វើជារបៀបការប្រជុំប្រមូលគំនិត (brainstorming session) ឬការពិគ្រោះយោបល់ជាក្រុមជំនាញ (focus group interviews)។ កិច្ចពិគ្រោះយោបល់លម្អិតអាចធ្វើឡើងតាមក្រោយ ប្រសិនបើតម្រូវឲ្យមាន FIA ។

- ពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីតម្លៃអាហារូបករណ៍ដែលត្រូវផ្តល់ជូនសិស្ស និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រីអំពីទម្រង់ ខ្លឹមសារនៃសេចក្តីព្រាង និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។
- ក្នុងដំណាក់កាលពិគ្រោះជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានការពិភាក្សាអំពីតម្លៃអាហារូបករណ៍ និងចំនួនសិស្សដែលទទួលបានអាហារូបករណ៍គឺ យើងជ្រើសរើសយកជម្រើសទី២ គឺអនុវត្តតាមវិសាលភាពពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២។
- ក្នុងដំណាក់កាលប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជម្រើសទី១ ក៏ត្រូវបានស្នើឡើង គឺអនុវត្តតាមវិសាលភាពពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។

## ៦. សន្និដ្ឋាន

សន្និដ្ឋានបឋមដោយផ្អែកលើប្រភេទចំណាយនិងផលចំណេញនៃជម្រើសនីមួយៗថាតើជម្រើសណាមួយត្រូវបានរំពឹងថានឹងផ្តល់ផលចំណេញច្រើនជាងគេ ឬមានបន្ទុកចំណាយច្រើនជាងគេ ឬមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង។

. តើចាំបាច់ធ្វើ FIA ដែរឬទេ?

☐ចាំបាច់ - *សូមបញ្ចប់ការវាយតម្លៃផលប៉ះពាល់បឋម (PIA) ហើយចាប់ផ្តើមរៀបចំការវាយតម្លៃផលប៉ះពាល់ពេញលេញ FIA បើសិនជាការប៉ាន់ស្មានបឋមលើបន្ទុកចំណាយមានតម្លៃចាប់ពី ១ លានដុល្លារអាមេរិក (សូមបញ្ជាក់ថាបន្ទុកចំណាយនេះគ្រាន់តែជាលក្ខណៈវិនិច្ឆ័យមួយប៉ុណ្ណោះក្នុងចំណោមលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត។ ក្នុងករណីបន្ទុកចំណាយតូចជាងនេះ ឬបន្ទុកចំណាយមានភាពស្មុគ្រស្មាញពេកពិបាកគណនា ប៉ុន្តែផលប៉ះពាល់មានវិសាលភាពធំ ប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង ...., .... ក៏តម្រូវឲ្យរៀបចំ FIA ផងដែរ។)*

☑មិនចាំបាច់ - *សូមផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃផលប៉ះពាល់បឋម (PIA) ដែលនៅសេសសល់។*

*(នេះត្រូវផ្អែកទៅលើកម្រិតនៃភាពសំខាន់នៃចំណាយកាតព្វកិច្ចបន្ថែម និងផលចំណេញហើយពិចារណាផង ថាតើមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ)។*

មិនចាំបាច់ធ្វើការវាយតម្លៃពេញលេញទេ(FIA) ដោយសារបន្ទុកចំណាយមានកម្រិតទាប បើធៀបនឹងថវិកាប្រចាំឆ្នាំរបស់ក្រសួង។

## ៧. ការអនុវត្ត និងការតាមដាន

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| ក្រសួងអប់រំ យុវជន និងកីឡាដែលនឹងអនុវត្តសេចក្តីព្រាងអនុក្រឹត្យថ្មីនេះ ត្រូវរៀបចំបង្កើតគណៈកម្មការ និងយន្តការបំពេញការងារ ដើម្បីសម្របសម្រួលក្នុងការអនុវត្តអនុក្រឹត្យនេះ ឱ្យស្របតាមគោលការណ៍អភិបាលកិច្ចល្អ (តម្លាភាព គណនេយ្យភាព ការចូលរួម និងការគោរពច្បាប់)។ |

៧.២. តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តានដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| គួរពិនិត្យបញ្ញត្តិកម្មនេះឡើងវិញរៀងរាល់ ៥ឆ្នាំម្តង ពីព្រោះសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជាមានការវិវត្តទៅមុខជានិច្ច ថ្លៃទំនិញតែងមានការកើនឡើង និងអំណាចទិញជាទូទៅមានការថយចុះ។ ម្យ៉ាងវិញទៀត ជីវភាពប្រជាពលរដ្ឋនឹងមានការអភិវឌ្ឍ តាមរយៈគោលនយោបាយកាត់បន្ថយភាពក្រីក្រក្នុងអត្រា១%ក្នុងមួយឆ្នាំ។ |

## អត្ថាធិប្បាយផ្សេងទៀត

| |
|---|
| តាមការវិភាគខាងលើបង្ហាញថា ជម្រើសដែលត្រូវពិចារណា ដើម្បីយកមកអនុវត្តគឺជម្រើសទី១ ដោយហេតុថាជ្រើសនេះផ្តល់ផលចំណេញផ្នែកសេដ្ឋកិច្ច សង្គមច្រើនជាងជម្រើសទី២ និងជម្រើសទី៣ បើទោះបី ជម្រើសនេះមានបន្ទុកចំណាយច្រើនជាង។ ដូច្នេះ ជាអនុសាសន៍ គួរជ្រើសរើសយកជម្រើសទី១។ |

| |
|---|
| ជម្រើសដែលគួរជ្រើសរើសនេះ នឹងផ្តល់ប្រាក់អាហារូបករណ៍ច្រើនជាងមុន ដែលអាចឆ្លើយតបនឹងស្ថានភាពថ្លៃទំនិញនៅលើទីផ្សារបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត ជម្រើសនេះនឹងជួយជំរុញទឹកចិត្តអ្នកសិក្សាក្នុងការខិតខំរៀនសូត្រ កាត់បន្ថយការបោះបង់ចោលការសិក្សាក្នុងចំណោមអ្នកសិក្សាដែលមានជីវភាពក្រីក្រ និងឈានឆ្ពោះទៅរកការសម្រេចបាននូវគោលនយោបាយទី១របស់ក្រសួងអប់រំ យុវជន និងកីឡា គឺជានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា | ឯកឧត្តម ស៊ិន សេងហុក | ប្រធាន | | | |
| | លោក ប៉ូវ វី | អនុប្រធាន | | | |
| | លោកស្រី ហេង ងួនឡាង | សមាជិក | | | |
| | លោក សឹង ប្រាក់ | សមាជិក | | | |
| ត្រួតពិនិត្យដោយ | លោកជំទាវ ស៊ាង សុផល្លា | | | | |
| ឯកភាពដោយ | ឯកឧត្តម ប៊ុច សុខា | | | | |